គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
លេខ.....គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី..... ខែ..... ឆ្នាំ២០១១

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារដើម្បីសិក្សាការរៀបចំបង្កើតមូលនិធិក្រុង ស្រុក ខណ្ឌ

លេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំការងារ កំណែទម្រង់វិមជ្ឈការ និងវិសហវិមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៦៩/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី ២៧ មករា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងការប្រព្រឹត្តរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥២១ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការតែងតាំងប្រធាន អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប
- យោងឯកសារផែនការអនុវត្តរយៈពេលពាក់ (ផអ៣២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃផអ៣

សម្រេច

ប្រការ ១.

ត្រូវបានបង្កើតក្រុមការងារមួយដើម្បីសិក្សារៀបចំបង្កើតមូលនីធិក្រុង ស្រុក ខណ្ឌ ។

ប្រការ ២.

ក្រុមការងារនេះ មានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម **លេង ទី**	អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប	ជាប្រធាន
២. លោក **យិន ម៉ាលីណា**	ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន	ជាអនុប្រធាន
៣. លោក **ស៊ី ឥរិន**	អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងជាសវនករផ្ទៃក្នុងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប	សមាជិក
៤. លោក **ឃីម ឆ**	មន្ត្រីការិយាល័យហិរញ្ញវត្ថុ	សមាជិក
៥. កញ្ញា **ជុំ ចំន្ទមុនី**	មន្ត្រីការិយាល័យហិរញ្ញវត្ថុ	សមាជិក
៦. លោក **ឧត ឥណ្ណៈ**	មន្ត្រីការិយាល័យហិរញ្ញវត្ថុ	សមាជិក
៧. លោក **ថាច់ សាវី**	ទីប្រឹក្សាគម្រោង IDLG	សមាជិក

ប្រការ ៣.

ក្រុមការងារនេះ មានតួនាទី និងភារៈកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំសេចក្តីព្រៀងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការអនុវត្តសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងព្រឡសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ ៤.

ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះនៅក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៥.

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប